


# សម្លេងទុគ៌តជន-Voice of the Poor

## ព្រឹត្តប័ត្រព័ត៌មាន ABiC–ABiC Newsletter

លេខ ០០២ វិច្ឆិកា ២០០៤ / No. 002 November 2004

ឧបត្ថម្ភដោយ/supported by USAID តាមរយៈ/through ARD Inc.



| បញ្ជីអត្ថបទ | ទំព័រ |
|---|---|
| ១. សហគមន៍ខិតខំការពារព្រៃឈើ (Communities' Effort to Protect Forests, p. 1) | ... ១ |
| ២. ហេតុអ្វីសហគមន៍ចង់ឱ្យមានសហគមន៍ព្រៃឈើ ? (Why Communities Want Community Forests, p. 3) | ... ៣ |


## សហគមន៍ខិតខំការពារព្រៃឈើ

ដោយមានតម្រូវការឈើសំរាប់យកទៅលក់បន្ត, យកទៅកែច្នៃជាសង្ហារឹមផ្សេងៗ និង នាំចេញខុសច្បាប់របស់ឈ្មួញមួយចំនួនតូច បច្ចុប្បន្នការកាប់បំផ្លាញព្រៃឈើដែលស្ថិតនៅក្នុងភូមិសាស្រ្តស្រុកស្ទួល នៅតែបន្ត ទោះជាមានការហាមប្រាមយ៉ាងតឹងរឹងពីរាជរដ្ឋាភិបាលក៏ដោយ ។ ប្រជាជនដែលរស់នៅក្នុងភូមិឃ្សឹម ឃុំឃ្សឹមស្រុកស្ទួល បានប្រាប់ឱ្យដឹងថា : រៀងរាល់ថ្ងៃជនល្មើសដែលមានខ្នងបង្អែកពីអ្នកមានអំណាចប្រមាណ ១០-១៥ នាក់បានចូលព្រៃ ដើម្បីកាប់យកឈើល្អដឹកចេញយកទៅលក់នៅកន្លែងផ្សេងៗពីក្នុងតំបន់ ។ ការដឹកចេញរបស់ជនល្មើសសព្វថ្ងៃនេះបានធ្វើឡើងក្នុងរូបភាពតូចៗ ដោយដាក់នៅក្នុងរថយន្តទំនើប និង ធ្វើការទាក់ទងជាមួយ មន្ត្រីរដ្ឋបាលព្រៃឈើខិលខូចដែលឈរជើងនៅទីនោះដោយផ្តល់ជាលាភសក្ការៈ ដើម្បីពួកគេអាចដឹកឈើទាំងនោះចេញយ៉ាងងាយស្រួល ។

ភាពអណាធិបតេយ្យនៃការកាប់បំផ្លាញព្រៃឈើបែបនេះ បានធ្វើឱ្យមានការប៉ះពាល់ដល់ការប្រកបមុខរបរ និង ជីវភាពរស់នៅរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ទាំងនោះព្រោះពួកគាត់តែងតែពឹងផ្អែកលើការប្រមូលផល-អនុផលព្រៃឈើសំរាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃ ។ នៅកន្លែងខ្លះទៀតជនល្មើស បានកាប់យកផ្តេកឈើខាងលើនៃច្បោះជ័ររបស់គាត់ថែមទៀតផង ។ បញ្ហានេះបានបង្កើតឱ្យមានជាទំនាស់រវាងប្រជាជនដែលរស់នៅក្នុងតំបន់ដែលមានការបំផ្លាញព្រៃឈើជាមួយនឹងអ្នកប្រកបមុខរបរកាប់ឈើខុសច្បាប់ ។

ដោយមានការបំពានយ៉ាងខ្លាំងក្លាពីសំណាក់ពពួកឈ្មួញទុច្ចរិតនិង ជនដែលប្រព្រឹត្តបទល្មើសក្នុងការកាប់បំផ្លាញព្រៃឈើ ប្រជាជនបានរួបរួមគ្នាប្រឆាំងក្នុងរូបភាពជាក្រុមតាមភូមិនិមួយៗ ហើយសកម្មភាពនេះត្រូវបានរីកសាយជាលំដាប់ពីភូមិមួយទៅភូមិមួយទៀត ដែលស្ថិតនៅក្នុងតំបន់មានការបំផ្លាញព្រៃឈើ ដោយមានកិច្ចសហការគ្នាទៅវិញទៅមកបង្កើតជាបណ្តាញសហគមន៍ការពារនិងទប់ស្កាត់បទល្មើសព្រៃឈើយ៉ាងសកម្មជាទីបំផុត ។ នៅក្នុងស្រុកស្នួលទាំងមូលមានប្រជាជនចំនួនបួនឃុំដែលបានរួមសាមគ្គីគ្នាបង្កើតជាសហគមន៍ ។ សហគមន៍ទាំងបួននេះត្រូវបានបង្កើតឡើងដោយប្រជាជនផ្ទាល់ និង បានបង្កើតជាគណៈកម្មការ ដើម្បីដឹកនាំសហគមន៍ ។ សហគមន៍ទាំងបួននេះត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើការល្បាតការពារ និង ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើពីសំណាក់ក្រុមប្រព្រឹត្តបទល្មើស ដោយគ្រាន់តែធ្វើការឃាត់វត្ថុតាងទុក និង រាយការណ៍ ព្រមទាំងប្រគល់ជូនដល់ស្ថាប័នជំនាញនៅក្នុងតំបន់គោលដៅ ពិសេសគឺរដ្ឋបាលព្រៃឈើ និង បរិស្ថាន ។

កន្លងមកប្រជាជនបានឃាត់វត្ថុតាងដូចជារណារយន្ត និង ឈើមូលបានជាច្រើន ហើយក៏បានធ្វើការប្រគល់ជូនដល់ស្ថាប័នជំនាញ ។ ជាក់ស្តែងកាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៤ សហគមន៍ក្នុងភូមិត្រពាំងល័ក្ខ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ បានចុះល្បាតហើយឃាត់វត្ថុតាងជារណារយន្តបានចំនួន បួន(០៤) គ្រឿង ដែលត្រូវបានជនល្មើសប្រើប្រាស់សម្រាប់កាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ដែលសហគមន៍បានខិតខំថែរក្សា ។ រាល់វត្ថុតាងទាំងនេះត្រូវបានប្រគល់ជូនទៅសង្កាត់រដ្ឋបាលព្រៃឈើឃ្សឹម ។

**Communities’ Effort to Protect Forests**

Even government’s moratorium on logging is still in effect illegal logging continues to take place in Snuol district. To protect the forest which is the important source of their livelihood people in four communes of Snuol district of Kratie province set up their network to protect and stop illegal logging.

They confiscated and handed over forensic materials (*corpus delicti*) such as logs, lumbers and chainsaws to local competent agencies such as forest administration and environment agencies. People hope that their effort would help to protect livelihood of their communities and of their future generations.

However, they have faced a lot of challenges and dangers as some corrupt local officials collude with the violators who sometimes threaten and abuse local people. For example, a staff of the Royal Cambodian Armed Force attacked a local community person by the head, who was later sent to Calmette Hospital in Phnom Penh for treatment. Even so, people will continue their effort, and wish that the government and relevant authorities provide them with support through imposing strict and effective measures and punishment of corrupt officials.

ប្រជាជនមានសង្ឃឹមថាការធ្វើបែបនេះអាចជួយការពារព្រៃឈើដែលជាអាយុជីវិតរបស់សហគមន៍គាត់ និង សម្រាប់កូនចៅជំនាន់ក្រោយរបស់ពួកគាត់ ។ ប៉ុន្តែក្នុងការធ្វើបែបនេះ ពួកគាត់ត្រូវប្រឈមមុខនឹងការលំបាក និង គ្រោះថ្នាក់ជាច្រើន ។ ពេលខ្លះក្រោយពីប្រគល់ជូនវត្ថុតាងទៅដល់ស្ថាប័នជំនាញ មន្ត្រីខិលខូចរបស់ស្ថាប័នជំនាញនោះបានឃុបឃិតជាមួយជនល្មើសលួចយកឧបករណ៍ ដែលរឹបអូសបាននោះយកមកប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសបន្តទៅទៀត ។ ពេលខ្លះជនល្មើសបានគំរាមអាយុជីវិត និង បង្កស្នាមរបួសដល់ប្រជាជនស្លូតត្រង់ទៀតផង ។ ជាក់ស្តែងកាលពីថ្ងៃទី ២៦ ខែ វិច្ឆិកា ២០០៤ ជនល្មើសដែលជាសមាជិកនៃកងយុទ្ធពលខេមរភូមិន្ទ បានចោលកែវចំក្បាលសមាជិកសហគមន៍ម្នាក់នៅទីសាធារណៈរហូតដល់មានគ្រោះថ្នាក់ត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែតក្រុងភ្នំពេញ ។

ទោះជាយ៉ាងណាក្តី ប្រជាជននៅតែខិតខំប្រឹងប្រែងបន្តទៀត ប៉ុន្តែពួកគាត់ក៏ត្រូវការឱ្យមានការជួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល និង សមត្ថកិច្ចជំនាញដែលពាក់ព័ន្ធ ដោយធ្វើយ៉ាងណាចាត់វិធានការ និង ដាក់ពិន័យដល់ជនល្មើស និង អ្នកដែលឃុបឃិត ឱ្យតឹងរ៉ឹង និង មានប្រសិទ្ធភាព ។

## ហេតុអ្វីសហគមន៍ចង់ឱ្យមានការបង្កើតសហគមន៍ព្រៃឈើ?

ការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព ជាការងារមួយដ៏សំខាន់ដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងដោយសហការយ៉ាងជិតស្និតជាមួយអង្គការជាតិ-អន្តរជាតិ និងស្ថាប័នផ្តល់ជំនួយនានា ។ ក្របខ័ណ្ឌច្បាប់ ដូចជាច្បាប់ភូមិបាល ច្បាប់ព្រៃឈើ អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ព្រះរាជក្រឹត្យស្តីពីការកំណត់តំបន់ការពារធម្មជាតិ និងការផ្តល់សិទ្ធិអំណាចគ្រប់គ្រងនិងប្រើប្រាស់ទៅឱ្យសហគមន៍មូលដ្ឋានដើម្បីថែរក្សានិងការពារឱ្យមាននិរន្តរភាពតាមបែបប្រព័ន្ធវិមជ្ឈការត្រូវបានបង្កើតឡើង និងអនុម័តឱ្យប្រើប្រាស់ ។

សកម្មភាពនៃការរៀបចំសហគមន៍ព្រៃឈើ មានការគាំទ្រយ៉ាងខ្លាំងក្លាពីស្ថាប័នជំនាញជាពិសេសគឺរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន និងអង្គការជាតិ-អន្តរជាតិ និងភ្នាក់ងារផ្តល់ជំនួយជាច្រើនទៀត ។ ទោះបីជាមានសហគមន៍ព្រៃឈើជាច្រើននៅក្នុងប្រទេសកម្ពុជាមិនទាន់បានការទទួលស្គាល់ជាផ្លូវការក៏ដោយ ក៏ប្រជាពលរដ្ឋក្នុងមូលដ្ឋានជាច្រើនបានយល់ថា ការបង្កើតសហគមន៍ដើម្បីការពារធនធានធម្មជាតិជាមធ្យោបាយមួយដ៏ល្អសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាពក្នុងតំបន់ជនបទ ។

មានតំណាងសហគមន៍ជាច្រើនបានមានប្រសាសន៍ថា ពួកគាត់ត្រូវការរៀបចំជាសហគមន៍ព្រៃឈើ ពីព្រោះនៅក្នុងឃុំរបស់គាត់កំពុងជួបប្រទះនូវបញ្ហាជាច្រើនក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើ និងដីធ្លី ។ ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងសហគមន៍លើការងារច្បាប់ពិសេសសិទ្ធិរបស់គាត់លើការប្រើប្រាស់ ការពារ និងការគ្រប់គ្រង ធនធានព្រៃឈើនិងដីធ្លីជាសហគមន៍នៅមានកំរិតទាបនៅឡើយ ។ ការបង្កើតសហគមន៍នៅមូលដ្ឋានបង្កលក្ខណៈមួយឱ្យប្រជាពលរដ្ឋខ្លួនឯងយល់ថា ព្រៃឈើនិងដីធ្លីនេះជាព្រទ្យសម្បត្តិរបស់សហគមន៍គាត់ទាំងអស់គ្នា ហើយគាត់អាចទទួលផលប្រយោជន៍ពីព្រៃឈើសហគមន៍តាមរយៈការប្រើប្រាស់ដែលមានផែនការត្រឹមត្រូវ មាននិរន្តរភាព គ្មានភាពអនាធិបតេយ្យ និងមានភាពម្ចាស់ការដោយខ្លួនឯង ។ តាមរយៈនៃការធ្វើសហគមន៍ព្រៃឈើ ប្រជាពលរដ្ឋនឹងបានយល់ដឹងពីច្បាប់ក្នុងការប្រើប្រាស់ និងគ្រប់គ្រងតាមរយៈការផ្សព្វផ្សាយរបស់មន្ត្រីនៃស្ថាប័នជំនាញ និងគណៈកម្មការព្រៃឈើសហគមន៍ ។

តាមបទពិសោធន៍ជាច្រើនរបស់សហគមន៍ព្រៃឈើបានបង្ហាញថា សហគមន៍មានយុទ្ធសាស្ត្រមួយចំនួនដើម្បីការពារ និងគ្រប់គ្រងស្របតាមច្បាប់ព្រៃឈើ និងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ។ យុទ្ធសាស្ត្រទាំងនោះរួមមានការបង្កើតជាលក្ខន្តិកៈសហគមន៍ ការរៀបចំផែនការប្រើប្រាស់ឱ្យមាននិរន្តរភាព ការរៀបចំសកម្មភាពផ្សព្វផ្សាយអំពីច្បាប់ និងការរៀបចំក្រុមល្បាត ដើម្បីការពារធនធានរបស់សហគមន៍ ។ ពេលជួបប្រទះបញ្ហាពួកគាត់តែងតែពិភាក្សាគ្នានៅក្នុងសហគមន៍ដើម្បីរិះរកការដោះស្រាយ ដូចជាក្នុងករណីមានសកម្មភាពបទ ល្មើសពិសេសបទល្មើសព្រៃឈើ ពួកគាត់តែងធ្វើសេចក្តីរាយការណ៍ ទៅឱ្យសមត្ថកិច្ចពាក់ព័ន្ធដូចជារដ្ឋបាល ព្រៃឈើ ឬ

**Why communities want community forests**

Sustainable use and management of natural resources is one of the critical commitments of the Royal Government of Cambodia (RGC) that has worked hard to get support from all stakeholders concerned. Legal frameworks have been put in place. The competent agencies of the RGC such as the Forest Administration (FA) and Ministry of Environment (MOE), donor agencies and NGOs have strongly supported the creation and operation of community forests.

The communities wish to set up community forests because they know that they would be able to protect and use their forests in a sustainable manner, and would be informed of relevant legal frameworks by competent agencies such as the FA and MOE, through legal extension activities. Recently, to support this quest the USAID through ARD Inc. provided a financial assistance to support the “Promotion and Strengthening of Legal Rights of Indigenous Communities to Forest and Land in accordance with the Forest and Land Laws” for the communities in Snuol Keo Seima and Oraing districts. The project is implemented by SSP with technical support of ABiC in close collaboration with the local FA, MOE, and local authorities and other concerned stakeholders.

បរិស្ថានជាដើម ។ ក្នុងករណីខ្លះពួកគាត់ឃាត់វត្ថុតាងទុកឱ្យនៅហ្នឹងកន្លែង ហើយធ្វើ សេចក្តីរាយការណ៍ និង ប្រគល់ជូនសមត្ថកិច្ច ។

ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះសហគមន៍មានការលំបាកខ្លាំង ដោយសារខ្វះខាតទាំងថវិកា និង បច្ចេកទេសសម្រាប់ការរៀបចំ និងដំណើរការសហគមន៍ព្រៃឈើ ។ បច្ចុប្បន្ននេះទើបតែមានសហគមន៍ព្រៃឈើតែពីរប៉ុណ្ណោះដែលបានការទទួលស្គាល់តាមផ្លូវច្បាប់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ ថ្មីៗនេះដើម្បីឆ្លើយទៅនឹងសេចក្តីត្រូវការបែបនេះ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក (USAID) បានផ្តល់ថវិកាគាំទ្រលើគំរោងមួយស្តីពី "ការលើកស្ទួយ និង ពង្រឹងសិទ្ធិស្របច្បាប់របស់សហគមន៍ជនជាតិដើមភាគតិចស្របតាមច្បាប់ភូមិបាល និងច្បាប់ព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា" តាមរយៈ ARD Inc. និង វិទ្យាស្ថាន-កេរ្យត្រពាណិជ្ជសាស្ត្រកម្ពុជាដែលហៅកាត់ថា ABiC និងអនុវត្តដោយអង្គការស្ត្រីសន្តិភាពដើម្បីបរិស្ថាន ដែលមានសកម្មភាពទាក់ទងនឹងការផ្សព្វផ្សាយអំពីសិទ្ធិស្របច្បាប់របស់សហគមន៍លើការប្រើប្រាស់ និងគ្រប់គ្រងព្រៃឈើ និងដីធ្លី សម្រាប់សហគមន៍ស្រុកស្ទួល ស្រុកកែវសីមា និង ស្រុកអូររាំង និងសកម្មភាពរៀបចំ សហគមន៍ព្រៃឈើនៅឃុំដាក់ដាំ តាមសេចក្តីស្នើសុំរបស់ តំណាងប្រជាពលរដ្ឋ រដ្ឋអំណាចមូលដ្ឋានភូមិ ឃុំ និងស្រុក ។ គំរោងនេះអាចសំរេចទៅបានជោគជ័យ លុះត្រាតែមានការចូលរួមយ៉ាងសកម្មពីស្ថាប័នជំនាញដូចជារដ្ឋបាលព្រៃឈើ មន្ទីរបរិស្ថាន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងរដ្ឋអំណាចមូលដ្ឋានដែលរួមមានភូមិ ឃុំ ស្រុក និង ខេត្ត និងការគាំទ្រពីអង្គការផ្សេងៗទៀតដែលកំពុងធ្វើការងារក្នុងតំបន់ ។ ABiC បានខិតខំសម្របសម្រួលពេញទំហឹងដើម្បីទទួលបានរាល់ការគាំទ្រ និង ការសហការអំពីអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនានា នៅក្នុងការអនុវត្តន៍គំរោងនេះ ។

